**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់សាកលវិទ្យាល័យអាស៊ាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨.៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២ .នស .៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦.០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពី ការបង្កើត ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អន.ក្រ ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពី ការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពី លក្ខណៈ វិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញលិខិតស្នើសុំ របស់លោក ស៊ុន សុវណ្ណរិទ្ធិ ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០២
- បានឃើញយោបល់របស់ក្រសួងអប់រំ យុវជន និង កីឡា

## សម្រេច

**មាត្រា ១ :** ទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា "សាកលវិទ្យាល័យអាស៊ាន" " ASEAN UNIVERSITY " ហៅកាត់ជាភាសាខ្មែរ " ស.អ " និងហៅកាត់ជា ភាសាអង់គ្លេស "A.U " ។

សាកលវិទ្យាល័យនេះស្ថិតនៅក្រោមឱវាទរបស់ក្រសួងអប់រំ យុវជន និង កីឡា និងមានទីតាំងគោល ស្ថិតនៅអាគារលេខ ១ ផ្លូវលេខ ១៣៩ សង្កាត់វាលវង់ ខណ្ឌ ៧មករា រាជធានីភ្នំពេញ ។

**មាត្រា ២ :** សាកលវិទ្យាល័យអាស៊ានធ្វើការបណ្តុះបណ្តាល :

- ថ្នាក់បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈរយៈពេលសិក្សាក្រោម ២ឆ្នាំ ។
- ថ្នាក់បរិញ្ញាប័ត្ររងសិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ត្រូវនឹង ៨៤ ក្រេឌីត ។
- ថ្នាក់បរិញ្ញាប័ត្រសិក្សារយៈពេលយ៉ាងតិច ៤ឆ្នាំ ត្រូវនឹង ១៦៥ ក្រេឌីត ។
- ថ្នាក់ម៉ាស្ទ័រសិក្សារយៈពេលយ៉ាងតិច ២ឆ្នាំ ត្រូវនឹង ៦០ ក្រេឌីត ។
- ថ្នាក់បណ្ឌិតសិក្សារយៈពេលយ៉ាងតិច ៣ឆ្នាំ ត្រូវនឹង ៥៤ ក្រេឌីត ។

**មាត្រា ៣ :** សាកលវិទ្យាល័យអាស៊ានមាន :

១- មហាវិទ្យាល័យ ពាណិជ្ជសាស្ត្រ និង ទេសចរណ៍

២- មហាវិទ្យាល័យ នីតិសាស្ត្រ និង សេដ្ឋកិច្ច

៣- មហាវិទ្យាល័យ ពត៌មានវិទ្យា

៤- មហាវិទ្យាល័យ វិទ្យាសាស្ត្រអប់រំ

៥- មជ្ឈមណ្ឌលបណ្តុះបណ្តាលថ្នាក់ជំនាញវិជ្ជាជីវៈ រយៈពេលសិក្សាក្រោម ២ឆ្នាំ

ទៅថ្ងៃអនាគត សាកលវិទ្យាល័យនេះអាចបើកមហាវិទ្យាល័យ ឬ សាខា ឬ ឯកទេស ដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៤ :** សាកលវិទ្យាល័យអាស៊ាន មានក្រុមប្រឹក្សាភិបាលមួយ ទទួលបន្ទុកការងារពិនិត្យនិងសំរេចលើគោលនយោបាយ និង ផែនការអភិវឌ្ឍរបស់សាកលវិទ្យាល័យ និង មានក្រុមប្រឹក្សាសិក្សាមួយដែលសមាជិកក្រុមប្រឹក្សានេះមានសញ្ញាប័ត្រកំរិតបណ្ឌិត សំរាប់ពិនិត្យ និង ផ្តល់យោបល់លើកម្មវិធីសិក្សា និង ការងារបច្ចេកទេសពាក់ព័ន្ធ ។

**មាត្រា ៥ :** លក្ខខណ្ឌទទួលសិស្សអោយចូលរៀន :

- ថ្នាក់បរិញ្ញាប័ត្ររង : បេក្ខជនត្រូវមានចំណេះដឹងទាបបំផុតបានសិក្សាបញ្ចប់ថ្នាក់ទី១២ នៃមធ្យមសិក្សាចំណេះទូទៅ ។
- ថ្នាក់បរិញ្ញាប័ត្រ : បេក្ខជនដែលមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ រឺ សញ្ញាប័ត្រ ដែលមានតំលៃស្មើ ។
- ថ្នាក់ម៉ាស្ទ័រ : បេក្ខជនដែលមានសញ្ញាប័ត្របរិញ្ញា រឺ សញ្ញាប័ត្រ ដែលមាន តំលៃស្មើ ។
- ថ្នាក់បណ្ឌិត : បេក្ខជន ដែលមានសញ្ញាប័ត្រម៉ាស្ទ័រ រឺ សញ្ញាប័ត្រ ដែលមាន តំលៃស្មើ ។

សាកលវិទ្យាល័យត្រូវគោរពតាមបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និង កីឡា ដែលកំនត់អំពីការជ្រើសរើសនិស្សិតអោយចូលរៀននៅតាមគ្រឹះស្ថានឧត្តមសិក្សា ។

**មាត្រា ៦ :** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យអាស៊ានមានភារកិច្ច :

- ទទួលខុសត្រូវនៅចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យ ។
- ជ្រើសរើស សិស្ស-និស្សិត អោយចូលរៀន និង ជ្រើសរើសសាស្ត្រាចារ្យមកបង្រៀន និងបុគ្គលិក បំរើការងារ ។
- គ្រប់គ្រងអោយបានល្អ នូវការងារនិស្សិត ការងារសិក្សា ការងារបង្រៀន ការងារស្រាវជ្រាវ និង ការប្រគល់សញ្ញាប័ត្រ ។
- គោរព និង អនុវត្ត តាមសារាចរ និង សេចក្តីណែនាំរបស់រាជរដ្ឋាភិបាល ។
- ធានាអោយបាន នូវសុវត្ថិភាព និង សណ្តាប់ធ្នាប់សង្គម ។
- ធ្វើរបាយការណ៍ រាល់សកម្មភាពសិក្សា ជូនក្រសួងអប់រំ យុវជន និង កីឡា អោយបានទៀងទាត់ តាមការកំណត់ ។

**មាត្រា ៧ :** និស្សិត ដែលរៀនចប់កម្មវិធីសិក្សា របស់សាកលវិទ្យាល័យនេះ និងទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាប័ត្រតាមកំរិត និង តាមឯកទេសដែលបានសិក្សា។ សញ្ញាប័ត្រនេះត្រូវបានផ្តល់អោយ ដោយសាកលវិទ្យាល័យអាស៊ាន ហើយត្រូវបានទទួលស្គាល់ពីក្រសួង អប់រំ យុវជន និង កីឡា ក្នុងករណី សាកលវិទ្យាល័យនេះបំពេញ និង អនុវត្តបាន តាមគោលការណ៍កំនត់របស់ ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៨ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា អគ្គនាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និង សាកលវិទ្យាល័យអាស៊ាន មានភារកិច្ចរៀង១ខ្លួន ដើម្បីអនុវត្ត និង ប្រតិបត្តិតាមអនុក្រឹត្យនេះ ។

**មាត្រា ៩ :** អនុក្រឹត្យនេះ មានប្រសិទ្ធិភាព និង គតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី២៤ ខែ មិថុនា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ

" ដើម្បីជ្រាប "

- ដូចមាត្រា ៨ "ដើម្បីអនុវត្ត
- ឯកសារ-កាលប្បវត្តិ